# កិច្ចការបញ្ចប់មេរៀនទី១០ សមាជិកគ្រួសារខ្ញុំ

**អំណាន:** ចូរអានអត្ថបទខាងក្រោម រួចឆ្លើយនឹងសំណួរ ។

គ្រួសារខ្ញុំ មានសមាជិកជាច្រើននាក់ ហើយម្នាក់ៗមានភារកិច្ចរៀងៗខ្លួន ។

ជីដូនជីតាខ្ញុំនៅផ្ទះថៃទាំចៅ ។ ពុកម៉ែខ្ញុំជាមេគ្រួសារ ។ គាត់ប្រកបរបររកស៊ីដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ និងតាមដានការរបស់កូន ។ មាមីងរបស់ខ្ញុំ ក៏ទៅធ្វើការដូចពុកម៉ែដែរ ។ ចំណែកបងប្រុស បងស្រី និងខ្ញុំមានភារកិច្ចសំខាន់ជាងគេ គឺខិតខំរៀនសូត្រដើម្បីមានអនាគតល្អ ។ ពួកយើងតែងជួបជុំទទួលទានអាហាររួមគ្នា និងជជែកកេងយ៉ាងសប្បាយរីករាយ ។

សមាជិកគ្រួសារខ្ញុំ រស់នៅប្រកបដោយសុភមង្គល ។

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើជីដូន ជីតានៅផ្ទះមានភារកិច្ចជួយធ្វើអ្វី ?

☐ ក. រៀបចំម្ហូបអាហារសម្រាប់គ្រួសារ ☐ ខ. ថៃទាំចៅៗ

☐ គ. តាមដានការសិក្សារបស់កូន ☐ ឃ. រកស៊ីចិញ្ចឹមគ្រួសារ

២. តើពុកម៉ែមានភារកិច្ចចម្បងអ្វីខ្លះ ?

☐ ក. រកស៊ី និងតាមដានការសិក្សារបស់កូន ☐ ខ. រៀបចំម្ហូបអាហារ

☐ គ. គិតតែរឿងរកលុយ ☐ ឃ. រកស៊ីចិញ្ចឹមគ្រួសារ

៣. តើកូនៗមានភារកិច្ចសំខាន់ធ្វើអ្វី ?

☐ ក. មើលប្អូន ☐ ខ. ជួយរកលុយ

☐ គ. ជួយធ្វើស្រែចម្ការ ☐ ឃ. ខិតខំរៀនសូត្រ

៤. តើកូនៗត្រូវធ្វើដូចម្ដេច ដើម្បីឱ្យឪពុកម្ដាយសប្បាយចិត្ត ?

☐ ក. ស្រឡាញ់ សាមគ្គី និងចេះជួយគ្នា ☐ ខ. ជួយធ្វើម្ហូប

☐ គ. ជួយរកលុយ ☐ ឃ.ជួយធ្វើស្រែ ចម្ការ

៥. ចូររកបដិសព្ទនឹងពាក្យ " សុភមង្គល " ។

☐ ក. មានក្ដីសុខ ☐ ខ. អពមង្គល

☐ គ. សប្បាយ ☐ ឃ.រីករាយ

៦. ចូររកបដិសព្ទនឹងពាក្យ " ជរា " ។

☐ ក. រឹងមាំ ☐ ខ. ថ្មី

☐ គ. ចាស់ ☐ ឃ. រឹងពឹង

LIVEWORKSHEETS

## សំណេរ

១. ចូរពន្យល់ខាងក្រោមឱ្យបានត្រឹមត្រូវ ។

- ជីវភាព ( ) ..........................................................................................។
- ភារកិច្ច ( )..........................................................................................។
- សុភមង្គល( )..........................................................................................។

២. ចូរកែតម្រូវពាក្យខុសដែលមានគូសបន្ទាត់ពីក្រោមឱ្យបានត្រឹមត្រូវ ។

| | |
|---|---|
| គ្រូសារខ្ញុំ មានសមាជីកជាច្រើននាក់ ។ ជីដូនជីតាខ្ញុំនូវផ្ទះមើលថៃថៅ។ ពុកម៉ែខ្ញុំជាមេគ្រូសារ គាត់ប្រកប់របររកស៊ីដើម្បីផ្គត់ផ្គងជីវភាពគ្រួសារ។ មាមីញខ្ញុំក៏ទៅធ្វើការដូចពុកម៉ែដែរ។ ពួកយើងតែងទទួលទានអារហាររួមគ្នា។ កូនៗមានភារកិច្ចសំខាន់ជាងគេគឺខិតខំរៀនសូតដើម្បីមានអនាគត់ល្អ។ | កំណែពាក្យត្រូវ<br>.................. .................. ..................<br>.................. .................. ..................<br>.................. .................. .................. |

៣. ចូររៀបពាក្យ ឬកន្សោមពាក្យខាងក្រោមជាល្បះឱ្យបានត្រឹមត្រូវ ។

| | | | | | | |
|---|---|---|---|---|---|---|
| សុភមង្គល | សមាជិក | ប្រកប | គ្រួសារ | ដោយ | រស់នៅ | ខ្ញុំ |

..........................................................................................................................

| | | | | | | |
|---|---|---|---|---|---|---|
| ធ្វើការ | ដើម្បី | ខ្ញុំ | ពុកម៉ែ | ជីវភាព | គ្រួសារ | ផ្គត់ផ្គង់ |

..........................................................................................................................

៤. ចូរតែងល្បះតាមរូបភាពខាងក្រោមឱ្យបានពីរល្បះ ។



ក/.........................................................

.............................................................

........................................................ ។

ខ/.........................................................

.............................................................

........................................................ ។

LIVEWORKSHEETS